**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

**សុន្ទរកថា**
**ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**
**ថ្លែងក្នុងឱកាសបើក**
**សន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២១ និងលើកទិសដៅឆ្នាំ ២០២២ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

**ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១**
**នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមបណ្តាញវីដេអូ កម្មវិធីZoom**

- *សូមគោរពអង្គពិធីទាំងមូល*
- *ឯកឧត្តម លោកជំទាវអនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍*
- *ឯកឧត្តម លោកជំទាវប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង ស្ថាប័ន រាជធានី ខេត្ត និងកាកបាទក្រហមកម្ពុជា។*
- *ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិជាទីរាប់អាន!*

តាងនាមអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដោយបានមកធ្វើជាអធិបតីក្នុងពិធីបើក **“សន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២១ និងលើកទិសដៅឆ្នាំ២០២២ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍”** ដ៏មានសារៈសំខាន់បន្ទាប់ពីកិច្ចប្រជុំពេញអង្គរបស់យើង ដែលបានប្រព្រឹត្តទៅកាលពីម្សិលមិញ។ ក្នុងឱកាសដ៏ប្រពៃនេះ ជាថ្មីម្តងទៀត ខ្ញុំសូមសម្តែងនូវអំណរគុណចំពោះវត្តមានដ៏មានតម្លៃរបស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ដែលចូលរួមនៅក្នុងសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២១ និងលើកទិសដៅសកម្មភាពសម្រាប់ឆ្នាំ២០២២ ក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា។

ក្នុងរយៈពេលមួយឆ្នាំកន្លងទៅនេះ ទោះបីជាស្ថិតនៅក្រោមការគំរាមកំហែងនៃជំងឺកូវីដ-១៩ ដែលទាមទារឱ្យយើងចេះរស់នៅ និងសម្របខ្លួនទៅតាមគន្លងថ្មីនេះយ៉ាងណាក្តី ក៏យើងបានបំពេញភារកិច្ចយ៉ាងសកម្មរួមគ្នា ដើម្បីឈានទៅបញ្ចប់ការឆ្លងរាលដាលមេរោគអេដស៍ និងជំងឺអេដស៍។ ការសន្យាប្រយុទ្ធនឹងជំងឺអេដស៍ និងភាពធ្វើជាម្ចាស់ក្នុងការដឹកនាំ នៅតែជាអាទិភាពដ៏សំខាន់បំផុតនៅក្នុងដំណើររបស់យើងទាំង

អស់គ្នា ឆ្ពោះទៅរកការបញ្ចប់ការរីករាលដាលនៃជំងឺអេដស៍ តាមគោលដៅ និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ដែលទាមទារឱ្យយើងទាំងអស់គ្នាខិតខំ ពុះពារ និងប្រឹងប្រែងបន្ថែមទៀត។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា!*

ខ្ញុំសូមជម្រាបជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី សមាជិកសមាជិកាអង្គសន្និបាតជ្រាបថា នៅក្នុងអង្គសន្និបាតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍នៅព្រឹកនេះ យើងនឹងមានបទបង្ហាញដូចតទៅ ៖

១. របាយការណ៍វឌ្ឍនភាពនៃការឆ្លើយតបទៅនឹងការឆ្លងរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ នៅកម្ពុជាប្រចាំឆ្នាំ២០២១ និងទិសដៅអនុវត្តឆ្នាំ២០២២ ដោយ **ឯកឧត្តម ឈឹម ឃិនជារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

២. បទបង្ហាញស្តីពីការចូលរួមកែលម្អគុណភាពសេវាដែលដឹកនាំដោយសហគមន៍ ដោយ **លោក ញឹម ជាឡៃន** ទីប្រឹក្សាបច្ចេកទេសអង្គការ FHI360 គម្រោង EpiC។

៣. បទបង្ហាញស្តីពីសមិទ្ធផលនៃគម្រោងពង្រឹងប្រព័ន្ធសហគមន៍គាំទ្របណ្តាញ និងវេទិកាសហគមន៍ (ហ្មុនប៉ាម និងឪហ្មុនប៉ាម) ដោយ **លោក ទឹម វ៉ា** នាយកប្រតិបត្តិអង្គការ HACC។

៤. បទបង្ហាញស្តីពីវឌ្ឍនភាពនៃការអនុវត្តគម្រោងទីក្រុងពន្លឿនការឆ្លើយតបនឹងមេរោគអេដស៍ និង ជំងឺអេដស៍ នៅខេត្តបាត់ដំបង បង្ហាញដោយ **លោកវេជ្ជ. ស៊ូ សានិត** អនុប្រធានមន្ទីរសុខាភិបាល និងជាប្រធានលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ខេត្តបាត់ដំបង។

៥. បទបង្ហាញស្តីពីវឌ្ឍនភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងការថែទាំ និងព្យាបាលឆ្នាំ២០២១ បង្ហាញដោយ **លោកវេជ្ជបណ្ឌិត អ៊ុក វិជ្ជា** អនុប្រធានក្តាប់រួមដឹកនាំ ការងារមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ (NCHADS)។

៦. បទបង្ហាញស្តីពី "បញ្ចប់វិសមភាព បញ្ចប់អេដស៍ បញ្ចប់ជំងឺឆ្លងរាតត្បាតសកល" ដោយ **ឯកឧត្តមវេជ្ជបណ្ឌិត ទា ផលា** អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

ហើយជាចុងក្រោយ គឺ ការប្រកាសទទួលស្គាល់សមិទ្ធផល ការងារឆ្លើយតបមេរោគអេដស៍ និងជំងឺ អេដស៍ ដល់សមាជិកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងអង្គការដៃគូ។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា!*

ខ្ញុំមានជំនឿថា រយៈពេលពេញមួយព្រឹកនេះ អង្គសន្និបាតរបស់យើងនឹងទទួលបានចំណេះដឹង និង បទពិសោធន៍ថ្មីៗបន្ថែមទៀត តាមរយៈការអនុវត្តជាក់ស្តែងរបស់សមាជិក សមាជិកានៃអង្គសន្និបាតដែល

អាចយកទៅប្រើប្រាស់កែលម្អ ដើម្បីឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅតាមក្រសួង ស្ថាប័ន រាជធានី ខេត្ត ឱ្យបានកាន់តែល្អប្រសើរថែមទៀត។ នៅក្នុងរបៀបវារៈចុងក្រោយ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍នឹងធ្វើការបូកសរុបនូវលទ្ធផលនៃអង្គសន្និបាតទាំងមូល។

ដើម្បីទុកពេលវេលាឱ្យបានច្រើនដល់ការធ្វើបទបង្ហាញ ការពិភាក្សា និងការចែករំលែកចំណេះដឹង ជំនាញ និងបទពិសោធន៍ក្នុងចំណោមសមាជិក សមាជិកានៃអង្គសន្និបាត ខ្ញុំសូមបញ្ចប់សុន្ទរកថាបើកអង្គសន្និបាតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ត្រឹមនេះ និងសូមប្រសិទ្ធពរជូនឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ឱ្យមានសុខភាពល្អ កម្លាំងមាំមួនក្នុងការចូលរួមពិភាក្សាឱ្យបានសកម្ម ដើម្បីទទួលបាននូវលទ្ធផលទៅតាមកម្មវត្ថុដែលបានគ្រោងទុក និងសូមប្រកាសបើក "**សន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២១ និងលើកទិសដៅឆ្នាំ២០២២ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**" ចាប់ពីពេលនេះតទៅ។

***សូមអរគុណ។***